00876921

E244/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
08 / 01 / 2013
ម៉ោង (Time/Heure): 15:05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣

**ជូនចំពោះ:** **ភាគីនៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង**
**មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ការអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាទាក់ទងទៅសាស្ត្រាចារ្យ Ben Kiernan ពាក់ព័ន្ធនឹងទំព័រទីពីរនៃឯកសារ E3/1173 ដែលបាត់**

១. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ឯកសារ E3/1173 ត្រង់ទំព័រទី ២ ហាក់ដូចជាបាត់ នៅពេលឯកសារនេះត្រូវបានដាក់កាលពីពេលថ្មីៗ (ឯកសារ ប.ក.ក ដែលមានចំណងជើងថា "មតិណែនាំរបស់ ៨៧០ អំពីការទម្លាក់គ្រាប់បែករបស់ចក្រពត្តិអាមេរិកលើក្រុងសៀមរាប ថ្ងៃ ២៥-២-៧៦") ។

២. កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យមានការទាក់ទងទៅសាស្ត្រាចារ្យ Ben Kiernan ដើម្បីបញ្ជាក់ថាតើគាត់មានឯកសារ E3/1173 ត្រង់ទំព័រទី ២ ដែលបាត់នោះដែរឬទេ (*សូមមើល* ឯកសារ E244)។ សហព្រះរាជអាជ្ញាបានយល់ព្រមទាក់ទងទៅសាស្ត្រាចារ្យ Kiernan ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ថាជាការសមស្រប។ គ្មានភាគីណាមួយបានជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានេះឡើយ។

៣. អង្គជំនុំជម្រះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាទាក់ទងទៅសាស្ត្រាចារ្យ Kiernan សម្រាប់មូលហេតុដូចដែលបានបញ្ជាក់នេះ ហើយប្រសិនបើសហព្រះរាជអាជ្ញាបានទទួលទំព័រដែលបាត់នោះ សហព្រះរាជអាជ្ញាត្រូវដាក់សាជាថ្មីនូវឯកសារ E3/1173 ទាំងមូល នាពេលសមស្របខាងមុខ។ សហព្រះរាជអាជ្ញាគប្បីបង្ហាញភាគី និងអង្គជំនុំជម្រះ នូវការឆ្លើយឆ្លងជាមួយសាស្ត្រាចារ្យ Kiernan ពាក់ព័ន្ធនឹងបញ្ហានេះ។